**នៅចំពោះមុខ អង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ)

ភាគីដាក់ឯកសារ: សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 21-Aug-2018, 14:36
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ **សម្ងាត់/Confidential**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើជាបន្ទាន់របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំពន្យារពេល និងបន្ថែមចំនួនទំព័រ ក្នុងការដាក់បណ្តឹងឧទ្ធរណ៍ជំទាស់នៅនឹងសេចក្តីសម្រេចពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២**

---

**ដាក់ដោយ៖**

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី÷**

ជេត វណ្ណលី
Daniel MCLAUGHLIN
សំ សុគង់
Nushin SARKARATI

**នៅចំពោះមុខ៖**

**អង្គបុរេជំនុំជម្រះ÷**

**ចៅក្រម ប្រាក់ គឹមសាន ប្រធាន**

**ចៅក្រម** Oliviver BEAUVALLET

**ចៅក្រម ន៉ីយ ថុល**

**ចៅក្រម** BAIK Kang Jin

**ចៅក្រម ហួត វុទ្ធី**

**ផ្ញើជូន៖**

**សហចៅក្រមស៊ើបអង្កេត**

**ចៅក្រម យូ ប៊ុនឡេង**

**ចៅក្រម Michael BOHLANDER**

**សហព្រះរាជអាជ្ញា៖**

**ជា លាង**

Nicholas KOUMJIAN

**សហមេធាវីការពារក្តី អោ អាន៖**

ម៉ុំ លុជ្ឈ

Richard ROGERS
Göran SLUITER

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ហុង គឹមសួន

គឹម ម៉េងឃី

ឡោ ជុនធី

វ៉េន ពៅ

ស៊ិន សុវ៉ែន

ទី ស្រីនណា

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN

## I. សេចក្តីផ្តើម

១. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើសុំដោយគោរពដល់អង្គបុរេជំនុំជម្រះ មេត្តាអនុញ្ញាតពន្យារពេល អនុលោមតាមវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង ក្នុងការដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាសម្រេចស្តីពីភាពអាចទទួលយកបាន នៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ដីកាសម្រេចស្តីពីភាពអាចទទួលយកបាន) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានចេញនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨[1]។ សហមេធាវីក៏ស្នើសុំដោយគោរពផងដែរសូមឲ្យបន្ថែមចំនួនទំព័រ និងការអនុញ្ញាតឲ្យដាក់បណ្តឹងឧទ្ធរណ៍ ជំទាស់ទៅនឹងសេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ តែមួយភាសាសិន។

២. ពាក្យសុំពន្យារពេលអាចទទួលយកបានដោយសារមានមូលហេតុចាំបាច់មួយចំនួន។ ដូចដែលនឹងពិភាក្សាខាងក្រោម ការឆ្លើយតបទៅនឹងការបដិសេធដើមបណ្តឹងរដ្ឋប្បវេណីដែលមានចំនួនដ៏ច្រើនសន្ធឹកសន្ធាប់នៅក្នុងសំណុំរឿង ០០៤/២ កាន់តែក្លាយបន្ទុកការងារដ៏ធ្ងន់ធ្ងរថែមទៀត ដោយសារមានបុគ្គលិក និង ធនធានតិចតួចស្តួចស្តើងសម្រាប់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយសហមេធាវីមិនអាចឆ្លើយតបឲ្យមានអត្ថន័យខ្លឹមសារទៅនឹងពាក្យសុំនីមួយៗដែលបានបដិសេធក្នុងរយៈពេល ១០ថ្ងៃ សម្រាប់ការដាក់បណ្តឹងឧទ្ធរណ៍ដែលឆាប់រហ័សបានឡើយ។ ហើយការពន្យារពេលក៏នឹងមិនធ្វើឲ្យមានហានិភ័យមិនចាំបាច់ដល់ប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធីលើបញ្ហានេះដែរ។ ដោយសារមានដីកាដំណោះស្រាយពីរដាច់ពីគ្នារបស់សហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលមិនធ្លាប់មានពីមុនមកនោះ អង្គបុរេជំនុំជម្រះប្រាកដជានឹងយកមកពិនិត្យអំពីបញ្ហាយុត្តាធិការបុគ្គលរបស់តុលាការចំពោះករណី អោ អាន មិនខាន។ ការពិនិត្យលើយុត្តាធិការរបស់តុលាការ ត្រូវមានអាទិភាពខ្ពស់ជាងការសម្រេចពីការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី ហើយបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាសម្រេចពីការទទួលយក នឹងត្រូវចាត់ទុកជាអសារបង់មុនគេ ដោយសារពុំមានយុត្តាធិការលើជនជាប់ចោទ។ ហេតុនេះ ការពន្យារពេលដាក់បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី នឹងមិនខូចខាតធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់ភាគីទេ។

---

[1] ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស ឯកសារ **D362** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

៣. ដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធី សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំការអនុញ្ញាត ដាក់សំណើនេះជាភាសាអង់គ្លេសជាមុនសិន ចំណែកសំណៅបកប្រែជាភាសាខ្មែរនឹងដាក់ជាក្រោយ។

## II. ប្រវត្តិនីតិវិធី

៤. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចរបស់ខ្លួនស្តីពី ភាពអាចទទួលយកបាន នៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ ("ដីកាសម្រេចស្តីពីភាពអាចទទួលយកបាន" ឬ "ដីកាសម្រេច") ដែលកំណត់អំពីបទដ្ឋាន សម្រាប់ភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំ រឿង ០០៤/២[2]។ នៅក្នុងដីកាដំណោះស្រាយដោយឡែកមួយ សហចៅក្រមស៊ើបអង្កេតជាតិបាន បដិសេធបទចោទទាំងអស់មកលើ អោ អាន ដោយសារមូលហេតុពុំមានយុត្តាធិការបុគ្គល ហើយ ហេតុនេះ គាត់មិនបានពិនិត្យទៅលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុង សំណុំរឿង ០០៤/២ ទេ។ ដីកាសម្រេចនេះត្រូវបានចេញជាភាសាខ្មែរតែមួយភាសា ដោយពុំមាន ការបកប្រែជាភាសាអង់គ្លេស ឬភាសាបារាំងទេ[3]។

៥. ឧបសម្ព័ន្ធ ខ នៃដីកាសម្រេច រៀបរាប់អំពីមូលដ្ឋាននានាដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មកយកសំអាងដើម្បីធ្វើការសន្និដ្ឋានថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១.៤០០ ក្នុងសំណុំរឿង ០០៤/២ មិនអាចទទួលយកបាន[4]។

## III. ច្បាប់ជាធរមាន

៦. វិធាន២៣ក្នុងចែងថា សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") អាចសម្រេចទៅលើភាពអាចទទួល យកបាននៃដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណាក់កាលស៊ើបអង្កេត តែក្រោយពេលចេញដីកា ដំណោះស្រាយរួច ស.ច.ស "ត្រូវសម្រេចអំពីភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជា

---

[2] ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេត អន្តរជាតិ សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស ឯកសារ **D362** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[3] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស ឯកសារ **D359** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[4] ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមិនត្រូវបានទទួលស្គាល់ សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស ឯកសារ **D362.2** ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៨។

ដើមបណ្ដឹងរដ្ឋប្បវេណីដែលនៅសេសសល់ទាំងអស់ ដោយដីកាដោយឡែក"[5]។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិប្ដឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្ដីសម្រេចពីការទទួលយក របស់សហចៅក្រមស៊ើបអង្កេត ដោយមិនផ្អាកកិច្ចដំណើរការនីតិវិធីទេ[6]។ បណ្ដឹងឧទ្ធរណ៍ស្ដីពីការទទួលយកដើមបណ្ដឹងរដ្ឋប្បវេណីស្ថិតក្នុងរបបនៃបណ្ដឹងឧទ្ធរណ៍ឆាប់រហ័សរបស់តុលាការ ដែលតម្រូវថា បណ្ដឹងឧទ្ធរណ៍ត្រូវដាក់ "ក្នុងរយៈពេល១០ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងនៃសេចក្ដីសម្រេចអំពីភាពអាចទទួលយកបាន" ជាថិរវេលាដែលពុំមានចែងអំពីការពន្យារពេលទេ[7]។

៧. សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានការចូលរួមយ៉ាងសមរម្យ និង មានអត្ថន័យខ្លឹមសារទៅក្នុងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក មានចែងទាំងនៅក្នុងវិធាននៃផ្ទៃក្នុង និង យុត្តិសាស្ត្ររបស់តុលាការ ព្រមទាំងគោលការណ៍ទូទៅនៃការចូលរួមរបស់ជនរងគ្រោះ ដែលមានចែងក្នុងច្បាប់អន្តរជាតិ ហើយតុលាការបានទទួលបានស្គាល់។ វិធាន ២១ នៃវិធានផ្ទៃក្នុងបង្កើតជាគោលការណ៍ជាសារវ័ន្តដែលណែនាំដល់ដំណើរការរបស់តុលាការ រួមទាំងថា វិធាន នីតិវិធី និងសេចក្ដីណែនាំអនុវត្តរបស់ អ.វ.ត.ក "ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និង *ជនរងគ្រោះ* ... ដោយគិតដល់*លក្ខណៈពិសេស*របស់ អ.វ.ត.ក"[8]។ អ.ប.ជ បានសន្និដ្ឋានថា ការបកស្រាយ និងការអនុវត្តច្បាប់ អ.វ.ត.ក ត្រូវធ្វើឡើងឲ្យស្របទៅនឹងលក្ខណៈពិសេសរបស់តុលាការ រួមទាំងបរិបទ កម្មវត្ថុ និងគោលបំណងរបស់តុលាការ ដែលរួមមាន ការធានានូវសិទ្ធិរបស់ជនរងគ្រោះក្នុង "ការចូលរួមដោយអត្ថន័យ" នៅក្នុងកិច្ចដំណើរការនីតិវិធី និង ការទទួលបានដំណោះស្រាយ[9]។ វិធាន ២១ ក៏តម្រូវផងដែរថា សិទ្ធិរបស់ជនរងគ្រោះត្រូវបាន "ការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្ដី"[10]។

---

[5] វិធានផ្ទៃក្នុង អ.វ.ត.ក (វិសោធនកម្មលើកទី៩) វិធាន ២៣*ស្ទួន*(៣)។

[6] វិធានផ្ទៃក្នុង អ.វ.ត.ក (វិសោធនកម្មលើកទី៩) វិធាន ២៣*ស្ទួន*(២)-(៣)។

[7] វិធានផ្ទៃក្នុង អ.វ.ត.ក (វិសោធនកម្មលើកទី៩) វិធាន ៧៧*ស្ទួន*(២)។

[8] វិធានផ្ទៃក្នុង អ.វ.ត.ក (វិសោធនកម្មលើកទី៩) វិធាន ២១(១) (គូសបញ្ជាក់បន្ថែម)។

[9] សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ) ឯកសារ **D404/2/4** ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ នៅត្រង់កថាខណ្ឌ ៥៨-៦៥ [តទៅនេះហៅថា "សាលដីការបស់ អ.ប.ជ លើភាពអាចទទួលបាននៃដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២"]។

[10] វិធានផ្ទៃក្នុង អ.វ.ត.ក (វិសោធនកម្មលើកទី៩) វិធាន ២១(១)(ក)។

៨. ជាងនេះទៀត នៅពេលវិធាននីតិវិធីមានភាពមិនច្បាស់លាស់ ឬបញ្ហាអង្គច្បាប់ប៉ះពាល់ដល់សិទ្ធិរបស់ជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក "គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ" និងនៅក្នុង "គោលការណ៍ទូទៅស្តីពីជនរងគ្រោះ នៅក្នុងច្បាប់អន្តរជាតិ"[11]។ គោលការណ៍ទាំងនេះអំពាវនាវឲ្យមានយន្តការតាមផ្លូវតុលាការសម្រាប់ដំណោះស្រាយដល់ជនរងគ្រោះដែល "ឆាប់រហ័ស ត្រឹមត្រូវ ... និងអាចអនុវត្តបាន"[12]។ គោលការណ៍ទាំងនេះក៏តម្រូវផងដែរថា ដំណើរការតាមផ្លូវតុលាការត្រូវ "ឆ្លើយតប" ទៅជនរងគ្រោះ ដោយ "អនុញ្ញាតឲ្យជនរងគ្រោះបង្ហាញការយល់ឃើញ និងការព្រួយបារម្ភ និង យកទៅពិចារណានៅដំណាក់កាលសមរម្យនៅក្នុងកិច្ចដំណើរការនីតិវិធី នៅពេលដែលផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេត្រូវបានប៉ះពាល់ ដោយមិនឲ្យខូចខាតប្រយោជន៍របស់ជនជាប់ចោទ"[13]។

## IV. ការពិភាក្សា

៩. ដើម្បីជាប្រយោជន៍យុត្តិធម៌ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគួរទទួលបានឱកាសសមរម្យ ត្រឹមត្រូវ អាចអនុវត្តបាន និង មានអត្ថន័យខ្លឹមសារ តាមរយៈមេធាវីរបស់ខ្លួន ដើម្បីលើកឡើងពីការយល់ឃើញ និង ការព្រួយបារម្ភរបស់ខ្លួន ឆ្លើយតបទៅនឹងការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅនឹងពាក្យសុំរបស់ខ្លួន នៅក្នុងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០៤/២ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី។

---

[11] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៧ នៅត្រង់មាត្រា ៣៣ថ្មី។ សាលដីការបស់ អ.ប.ជ លើភាពអាចទទួលបាននៃដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ *ខាងលើ* ជើងទំព័រ ៩ នៅត្រង់កថាខណ្ឌ ៣២។

[12] សេចក្តីប្រកាសស្តីពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារឧក្រិដ្ឋកម្ម និង ការបំពានអំណាច សេចក្តីសម្រេចរបស់មហាសន្និបាត អ.ស.ប លេខ 40/34 ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ នៅត្រង់គោលការណ៍ ៥ [តទៅនេះហៅថា "សេចក្តីប្រកាសរបស់ អ.ស.ប ស្តីពីការបំពានអំណាច"]។ *សូមមើលផងដែរ* សេចក្តីប្រកាសស្តីពីគោលការណ៍ជាមូលដ្ឋាន និង ការណែនាំស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និង សំណងដល់ជនរងគ្រោះពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និង ការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ សេចក្តីសម្រេចរបស់មហាសន្និបាត អ.ស.ប លេខ 60/147 ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥ នៅត្រង់គោលការណ៍ ១១ [តទៅនេះហៅថា "គោលការណ៍ជាមូលដ្ឋានរបស់ អ.ស.ប ស្តីពីសិទ្ធិទទួលបានដំណោះស្រាយ"]។

[13] សេចក្តីប្រកាសរបស់ អ.ស.ប ស្តីពីការបំពានអំណាច *ខាងលើ* ជើងទំព័រ ១២ នៅត្រង់គោលការណ៍ ៦(ក)-(ខ)។

១០. ដោយសារវិសាលភាពធំធេងនៃការបដិសេធនៅក្នុងដីកាសម្រេចពីការទទួលយក និងធនធានតិចតួចស្តួចស្តើង ដែលមេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចប្រើប្រាស់បាន សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំពន្យារពេល ៣០ថ្ងៃ ដើម្បីឆ្លើយតបទៅនឹងដីកាសម្រេចពីការទទួលយក។ ការពន្យារពេលនេះនឹងផ្តល់ពេលវេលាគ្រប់គ្រាន់ដើម្បីពិគ្រោះយោបល់ជាមួយកូនក្តី ទទួលបានព័ត៌មានបន្ថែម ឬ ឯកសារនានាដែលចាំបាច់ដើម្បីគាំទ្រដល់បណ្តឹងឧទ្ធរណ៍ និង រៀបចំមូលដ្ឋាននានាសម្រាប់ដាក់សារណាដល់អង្គបុរេជំនុំជម្រះ។

១១. ការពន្យារពេលក្នុងការដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាសម្រេចពីការទទួលយក ក្នុងសំណុំរឿង ០០៤/២ រហូតដល់រយៈពេល ៣០ថ្ងៃ នឹងផ្តល់ឱកាសកាន់តែទូលំទូលាយដល់សហមេធាវីក្នុងការជួបប្រាស្រ័យទាក់ទងជាមួយកូនក្តី ដែលភាគច្រើនរស់នៅតាមទីជនបទឆ្ងាយដាច់ស្រយាលនៅទូទាំងប្រទេស និង នៅឯបរទេស ហើយមានឱកាសបានពិគ្រោះយោបល់យ៉ាងមានអត្ថន័យខ្លឹមសារជាមួយពួកគេ ដើម្បីដាក់ការជំទាស់មួយដែលមានមូលដ្ឋានត្រឹមត្រូវ ទៅនឹងការសន្និដ្ឋានមិនទទួលយក របស់សហចៅក្រមស៊ើបអង្កេតនោះ។ នៅឯដំណាក់កាលសំខាន់នៃកិច្ចដំណើរការនីតិវិធីនេះ នៅពេលដែលសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានការចូលរួមយ៉ាងពេញលេញស្ថិតក្នុងស្ថានភាពស្រពិចស្រពិលបែបនេះ ការពិគ្រោះយោបល់មានសារៈសំខាន់ណាស់ ប្រសិនបើតុលាការពិតជាបំពេញភារកិច្ចរបស់ខ្លួន ដើម្បីការពារផលប្រយោជន៍របស់ជនរងគ្រោះ និង គោរពដល់សិទ្ធិរបស់ពួកគេក្នុងការទទួលបានការចូលរួមយ៉ាងមានអត្ថន័យខ្លឹមសារ តាមរយៈដំណើរការបណ្តឹងឧទ្ធរណ៍ដែលអាចទទួលបាន មែននោះ។

១២. ជាងនេះទៀត ការសម្រេចរបស់អង្គបុរេជំនុំជម្រះក្នុងការអនុញ្ញាតឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានពេលវេលាបន្ថែម នឹងមិនធ្វើឱ្យខូចខាតប្រយោជន៍របស់ភាគីផ្សេងទៀត ហើយក៏មិនប៉ះពាល់ដល់ប្រសិទ្ធិភាពនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤/២ ដែរ។ ជាបញ្ហាបឋម ការចេញសេចក្តីសម្រេចដាច់ដោយឡែកពីគ្នារវាងសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានធ្វើឱ្យមានភាពមិនប្រក្រតីផ្នែកនីតិវិធីស្រេចទៅហើយ ហើយស្ថានភាពរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ នៅក្នុងសំណុំរឿង ០០៤/២ ស្ថិតក្នុងភាពមិនច្បាស់លាស់ រហូតទាល់តែបញ្ហាយុត្តាធិការបុគ្គលរបស់តុលាការទៅលើ អោ អាន ត្រូវបានដោះស្រាយ។ ដោយហេតុថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅតែមានសិទ្ធិក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី រហូតទាល់តែមានសេចក្តី

សម្រេចស្ដាពរស្ដីពីភាពអាចទទួលយកបានរបស់ពួកគេនោះ មានហេតុផល ឬភាពចាំបាច់តិចតួច ដែលតុលាការត្រូវសម្រេចទៅលើបណ្ដឹងឧទ្ធរណ៍ពីការទទួលយកដើមបណ្ដឹងរដ្ឋប្បវេណីនៅដំណាក់កាលនេះ។

១៣. នៅ អ.វ.ត.ក ជនរងគ្រោះមានសិទ្ធិទទួលបានវិធានការការពារ និងសេចក្ដីពិចារណាពេញលេញ ទៅតាមគោលការណ៍ជាសារវ័ន្តរបស់ច្បាប់ វិធានរបស់តុលាការ និងគោលការណ៍ទូទៅរបស់ច្បាប់អន្តរជាតិ។នៅក្នុងបញ្ហានីតិវិធី ដូចជាការអនុញ្ញាតផ្ដល់ពេលវេលាក្នុងការដាក់បណ្ដឹងឧទ្ធរណ៍ ចៅក្រមអង្គបុរេជំនុំជម្រះបានធ្វើការកត់សម្គាល់ពី “ភាពចាំបាច់ជាសារវ័ន្ត ... ដើម្បីធានា ចំពោះការគោរពនីតិវិធីដែលបានបង្កើតឡើងដើម្បីទទួលបាន “ភាពយុត្តិធម៌ទៅតាមនីតិវិធី” មិនមែនដើម្បី “ភាពយុត្តិធម៌ ទៅតាមលទ្ធផលដែលខ្លួនចង់បាន” នោះទេ”[14]។ ការអនុញ្ញាតទៅតាមសំណើសុំពន្យារពេល អង្គបុរេជំនុំជម្រះនឹងធានាថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទទួលបានយុត្តិធម៌ទៅតាមនីតិវិធី ពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍របស់ពួកគេ ស្ដីពីភាពទទួលយកបាន។

## V. សំណើ

១៤. អនុលោមតាមសំអាងហេតុនានាដែលបានលើកឡើងខាងលើ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំដោយគោរពដល់អង្គបុរេជំនុំជម្រះ មេត្តា៖

ក. **ពន្យារ**ពេលកំណត់ សម្រាប់ដាក់បណ្ដឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្ដីសម្រេចស្ដីពីភាពអាចទទួលយកបាននៃដើមបណ្ដឹងរដ្ឋប្បវេណីរយៈពេល ៣០ថ្ងៃ។

ខ. **បន្ថែម**ចំនួនទំព័រសម្រាប់ដាក់បណ្ដឹងឧទ្ធរណ៍ស្ដីពីភាពអាចទទួលយកបាននៃដើមបណ្ដឹងរដ្ឋប្បវេណីរហូតដល់ ៤៥ទំព័រ។ និង

[14] មតិយោបល់របស់ចៅក្រម Lahuis និង ចៅក្រម Downing សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចស្ដីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីលោក រ៉ូប៊ីត ហាមីល (Robert Hamill) សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០២) ឯកសារ **D11/2/4/4** ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ នៅឯកថាខណ្ឌ ១០។

គ. **អនុញ្ញាត**ឲ្យសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួន តែមួយភាសាសិន អាចជាភាសាខ្មែរ ឬភាសាអង់គ្លេស ចំណែកសំណៅបកប្រែនឹងដាក់តាមក្រោយ។

សូមលោកចៅក្រមមេត្តាទទួលយកចម្លើយតបនេះដោយក្តីគោរព

| កាលបរិច្ឆេទ | នាម និងគោត្តនាម | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ | **សំ សុគង់**<br>សហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ភ្នំពេញ<br>ប្រទេសកម្ពុជា | |
| | **Nushin SARKARTI**<br>សហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ភ្នំពេញ<br>ប្រទេសកម្ពុជា | |
| | **Daniel MCLAUGHLIN**<br>សហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ភ្នំពេញ<br>ប្រទេសកម្ពុជា | |
| | **ជេត វណ្ណលី**<br>សហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ភ្នំពេញ<br>ប្រទេសកម្ពុជា | |